## តំបន់លម្ហសមុទ្រអន្តរជាតិ ( High Sea)

-តំបន់សមុទ្រនេះ ត្រូវចាត់ថាជាតំបន់ហួសយុត្តាធិការរបស់រដ្ឋជាប់ឆ្នេរ ដោយវាតភ្ជាប់ពីចំណុចនៃផ្នែកខាងក្រៅនៃតំបន់សេដ្ឋកិច្ចផ្តាច់មុខរបស់រដ្ឋទៅកាន់លម្ហសមុទ្រ។

-តំបន់នេះជាតំបន់រួម និងបើកសេរីសម្រាប់រដ្ឋទាំងអស់ រួមទាំងរដ្ឋមិនជាប់សមុទ្រផង។ គ្មានរដ្ឋណាមួយអាចទាមទារអធិបតេយ្យលើតំបន់លម្ហសមុទ្រអន្តរជាតិឡើយ ប៉ុន្តែក្នុងតំបន់នេះ រដ្ឋមានយុត្តាធិការផ្តាច់មុខលើនាវាដែលបំពាក់ទង់ជាតិរបស់ខ្លួន។

-រដ្ឋទាំងអស់មានសិទ្ធិដូចៗគ្នា ក្នុងការប្រើប្រាស់លំហលម្ហសមុទ្រអន្តរជាតិ ដូចជាសេរីភាពនាវាចរណ៍ សេរីភាពហោះហើរពីលើ សេរីភាពដាក់ពង្រាយខ្សែកាប្លិ៍ និងបង្ហូរបំពង់ប្រេងក្រោមបាតសមុទ្រ សេរីភាពសាងសង់កោះសិប្បនិម្មិតនិងឋបនាការ សេរីភាពស្រាវជ្រាវវិទ្យាសាស្ត្រសមុទ្រជាដើម ( UNCLoS, មាត្រា៨៧ )។

-រដ្ឋទាំងអស់ត្រូវប្រើប្រាស់លម្ហសមុទ្រអន្តរជាតិ ដោយសន្តិវិធី និងសហការក្នុងការអភិរក្សធនធានមានជីវិត និងអនុវត្តយុត្តាធិការលើកប៉ាល់ដោតទង់របស់ខ្លួន។